ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Jan-2015, 11:15
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជតក

ដាក់ទៅ : អង្គជំនុំជម្រះតុលាការកំពូល

ថ្ងៃដាក់ : ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥

ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា

ភាសាដើម : អង់គ្លេស

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងចម្លើយតបរបស់មេធាវីការពារក្ដីទៅនឹងសំណើសុំឲ្យដោះស្រាយចំពោះវិការៈនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះតុលាការកំពូល:

ចៅក្រម គង់ ស្រឹម, ប្រធាន

ចៅក្រម A. KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម C.N. JAYASINGHE

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Florence Ndepele MUMBA

ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:

លោក ពេជ អង្គ

លោកស្រី Marie GUIRAUD

ជនជាប់ចោទ:

នួន ជា

ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:

លោក សុន អរុណ

លោក Victor KOPPE

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

## ការឆ្លើយតប

### I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

1. នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាត្រូវបានជូនដំណឹងអំពីការដាក់បណ្តឹងសាទុក្ខ ("សេចក្តីជូនដំណឹង") ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១ ("សាលក្រម")[1]។ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ខៀវ សំផន បានដាក់សារណាបណ្តឹងសាទុក្ខរបស់គាត់ ("បណ្តឹងសាទុក្ខ") ជូនទៅអង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ")។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ខៀវ សំផន បានដាក់សំណៅកែតម្រូវមួយ ("បណ្តឹងសាទុក្ខកែតម្រូវ")[2]។

2. នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យ អង្គជំនុំជម្រះបង្គាប់ឱ្យមេធាវីការពារក្តី ខៀវ សំផន ("មេធាវីការពារក្តី") ដោះស្រាយចំពោះវិការៈទាំងឡាយដែលទុកឱ្យភាគីនានាមិនច្បាស់លាស់អំពីខ្លឹមសារ និងវិសាលភាពនៃបណ្តឹងសាទុក្ខ("សំណើ")[3]។ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ មេធាវីការពារក្តីបានដាក់ចម្លើយតបរបស់ខ្លួន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា("ចម្លើយតប")[4]។ នៅក្នុងចម្លើយតបរបស់នោះ មេធាវីការពារក្តីបានជំទាស់ទៅនឹងសំណើដោយបានចាត់ទុកសំណើនោះថា គ្មានហេតុផល និងឥតប្រយោជន៍[5]។ ពួកគាត់បានលើកឡើងថាសេចក្តីជូនដំណឹងកែតម្រូវនោះ គឺច្បាស់លាស់ ហើយថាសហព្រះរាជអាជ្ញាមានការច្រឡំគ្នារវាងលេខកថាខណ្ឌ និងទម្លីករណ៍នៃបណ្តឹងសាទុក្ខ[6]។ យ៉ាងដូច្នេះក៏ដោយ ក៏មេធាវីការពារក្តីបានផ្តល់ឧបសម្ពន្ធបន្ថែមមួយ ដោយមានតារាងដែលភ្ជាប់លេខកថាខណ្ឌនៃសេចក្តីជូនដំណឹង ទៅនឹងកថាខណ្ឌដែលស៊ីគ្នាទាំងឡាយនៅក្នុងបណ្តឹងសាទុក្ខកែតម្រូវ[7]។

---

[1] **E313/2/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១, ២៩ កញ្ញា ២០១៤ ("សេចក្តីជូនដំណឹង")។

[2] **F17/Corr. 1** Mémoire d'appel de la Défense de M.KHIEU Samphân contre le jugement rendu dans le procès 002/01, ៣១ ធ្នូ ២០១៤ ត្រង់ FR 01052205 ("បណ្តឹងសាទុក្ខកែតម្រូវ")។

[3] **F18** សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យដោះស្រាយចំពោះវិការៈនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន, ៦ មករា ២០១៥ ("សំណើ")។

[4] **F18/1** ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹង "សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យដោះស្រាយចំពោះវិការៈនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន", ១២ មករា ២០១៥ ("ចម្លើយតប")។

[5] *ដដែលដូចមុន*, ត្រង់កថាខណ្ឌទី៥។

[6] *ដដែលដូចមុន*, ត្រង់កថាខណ្ឌទី៩។

[7] *ដដែលដូចមុន*, ឧបសម្ពន្ធ។

3. សហព្រះរាជអាជ្ញាស្នើការអនុញ្ញាតដាក់ចម្លើយតបនេះជាភាសាអង់គ្លេស ដូចបានកំណត់ក្នុងមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តជាធរមាន ដោយភាសាខ្មែរនឹងដាក់តាមក្រោយ ហើយអាចដាក់ក្នុងរយៈពេល២៤ម៉ោង។ សហព្រះរាជអាជ្ញាធ្វើដូចនេះ គឺចំពោះតែកាលៈទេសៈដោយឡែកប៉ុណ្ណោះ ដោយហេតុថា មានភាពបន្ទាន់ចំពោះការបញ្ចប់ដំណាក់កាលធ្វើបណ្តឹងសាទុក្ខនេះ និងមានពេលកម្រិតសម្រាប់ដាក់ចម្លើយតបពាក់ព័ន្ធនឹងអង្គសេចក្តីក្នុងបណ្តឹងសាទុក្ខនេះ។

## II. សេចក្តីផ្តើម

4. ចម្លើយតបនេះចាំបាច់ដើម្បីបញ្ជាក់ពីប្រភេទនៃសំណើដើម និងដើម្បីបញ្ជាក់ពីសារៈសំខាន់នៃដំណោះស្រាយដែលបានស្វែងរក។ សរុបមក សូមសន្និដ្ឋានថា បណ្តឹងសាទុក្ខដែលបានកែតម្រូវរួមជាមួយចម្លើយតបនេះ នៅតែមានវិការៈដដែលត្រង់ចំណុចដែលមិនបានបញ្ជាក់នូវមូលហេតុនីមួយៗនៃបណ្តឹងសាទុក្ខដែលបានប្តឹង ដូចមានចែងក្នុងវិធាន១០៥ នៃវិធានផ្ទៃក្នុង[8]។ ការខកខាននេះមិនចំពោះតែការរំលោភវិធានជាក់ស្តែងទេ និងបទដ្ឋានដែលតម្រូវក្នុងការលើកទឡ្ហីករណ៍សម្រាប់បណ្តឹងសាទុក្ខដូចដែលបានកំណត់នៅក្នុងយុត្តិសាស្ត្ររបស់ អវតក និងអន្តរជាតិដែលពាក់ព័ន្ធ[9]។ ប៉ុន្តែជាងនេះទៀត វិការៈនេះបង្ហាញនូវការលំបាកច្រើនពិតប្រាកសម្រាប់ភាគីទាំងអស់

[8] វិធាន១០៥(៣) នៃវិធានផ្ទៃក្នុងចែងថា៖ ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង **ត្រូវ**ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ។ ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ **ដែលបញ្ជាក់ពីមូលដ្ឋាននីមួយៗ** ត្រូវបញ្ជាក់ពីកំហុសអង្គច្បាប់ ដែលនាំឲ្យសេចក្តីសម្រេចនោះមោឃៈ និងកំហុសអង្គហេតុ ដែលនាំឲ្យសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ បន្ទាប់មក ម្ចាស់បណ្តឹងសាទុក្ខ **ត្រូវ**ដាក់សារណាបណ្តឹងសាទុក្ខដោយបញ្ជាក់ពីទឡ្ហីករណ៍ និង**ឯកសារសម្អាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗ** អនុលោមតាមលក្ខខណ្ឌនៅក្នុងវាក្យខណ្ឌទី ២(ក) និង(គ) នៃវិធាននេះ។ [សង្កត់ន័យបន្ថែមដោយ **អក្សរដិតក្រាស់**]។

[9] ដោយយោងតាមអង្គជំនុំជម្រះ ម្ចាស់បណ្តឹងសាទុក្ខត្រូវតែដាក់បណ្តឹងរបស់ខ្លួនដោយ "ជាក់លាក់គ្រប់គ្រាន់" ដើម្បីឲ្យ អជតក មានលទ្ធភាព "កំណត់បញ្ហាវិវាទ ដោយយោងទៅលើសម្អាងហេតុជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូង", សូមអាន **CF001-F28** សាលដីកា, ៣ កុម្ភៈ ២០១២ ("សាលដីកាលើសំណុំរឿងរបស់ *ឌុច*"), ត្រង់កថាខណ្ឌទី៤១។ អង្គជំនុំជម្រះនេះបានសម្រេច ស្រដៀងគ្នានេះដែរថា ជាវិធានទូទៅគេតម្រូវឲ្យម្ចាស់បណ្តឹងសាទុក្ខដាក់ឲ្យបានច្បាស់លាស់ និងឲ្យមានតម្លាភាព នូវទឡ្ហីករណ៍នានា នៃបណ្តឹងសាទុក្ខដែលប្រឆាំងនឹងសេចក្តីសម្រេច និងត្រូវដាក់សម្អាងហេតុសំខាន់ៗដើម្បីគាំទ្រ, *ដដែលដូចមុន* ។ សូមអានផងដែរ *រដ្ឋអាជ្ញា ទល់នឹង Ntakirutimana*, សំណុំរឿងលេខ ICTR-96-1O-A និង ICTR-96-17-A, "សាលដីកា", អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ១៣ ធ្នូ ២០០៤ ("សាលដីកាលើសំណុំរឿងរបស់ *Ntakirutimana* "), កថាខណ្ឌទី៣៩០។ *រដ្ឋអាជ្ញា ទល់នឹង Kordic* និង Cerkez, សំណុំរឿងលេខ IT-95-14/2-A, "សាលដីកា", អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ១៧ ធ្នូ ២០០៤ ("សាលដីកាលើសំណុំរឿងរបស់ Kordic និង Cerkez"), កថាខណ្ឌទី២៣។ រដ្ឋអាជ្ញា ទល់នឹង Kvocka, សំណុំរឿងលេខ IT-98-30/1-A, "សាលដីកា", អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ២៨ កុម្ភៈ ២០០៥ ("សាលដីកាលើសំណុំរឿងរបស់ Kvocka"), កថាខណ្ឌទី៤២៥។

និងសំខាន់ជាងនេះចំពោះអង្គជំនុំជម្រះតុលាការកំពូល សម្រាប់បញ្ហាសេសសល់ក្នុងដំណើរការបណ្តឹងសាទុក្ខនេះ។

5. ដូចបញ្ហានាពេលនេះ មូលហេតុច្បាស់លាស់នៃបណ្តឹងសាទុក្ខដែលមេធាវីការពារក្តីកំពុងលើកនេះ មិនបានបញ្ជាក់ច្បាស់ និងមិនបានរៀបរាប់ឲ្យបានមួយៗ ដោយបន្សល់ទុកនូវខ្លឹមសារមិនច្បាស់លាស់ទាំងអស់។ ការបញ្ជាក់អំពីបញ្ហានេះ គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងដំណាក់កាលដំណើរការបណ្តឹងសាទុក្ខនេះ និងនឹងជួយខ្លាំងដល់ការធានាឲ្យមានដំណើរការប្រកបដោយសមត្ថភាព និងប្រសិទ្ធភាព តាមរយៈការធានានូវបូរណភាពនៃដំណើរការនីតិវិធី។

## III. អំណះអំណាង

6. ក្នុងសំណើនេះ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា បណ្តឹងសាទុក្ខដែលបានកែតម្រូវបានដកចេញនូវមូលហេតុយោងបន្ទាប់បន្សំដែលមាននៅក្នុងការជូនដំណឹងបណ្តឹងសាទុក្ខ ដែលយោងទៅដល់មូលហេតុជាច្រើននៃបណ្តឹងសាទុក្ខនេះ។ ដោយគិតជាមួយនឹងការផ្លាស់ប្តូរនៅក្នុងកថាខណ្ឌដែលបានវាយលេខ រវាងសេចក្តីជូនដំណឹង និងបណ្តឹងសាទុក្ខកែតម្រូវ សហព្រះរាជអាជ្ញាបានអះអាងថា វាក្លាយទៅជាការពិបាកមួយក្នុងការកំណត់ឲ្យបានជាក់លាក់ណាស់ ថាតើទឡ្ហីករណ៍ណាខ្លះនៃបណ្តឹងសាទុក្ខដែលនៅពេលនេះ ត្រូវបានចោទប្រកាន់ដោយមេធាវីការពារក្តី ហើយថាតើតាមពិតទៅមានទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខមួយចំនួនត្រូវបានបោះបង់ចោលដែរ ឬមួយយ៉ាងណា[10]។ សហព្រះរាជអាជ្ញាបានអះអាងថា របៀបដែលបណ្តឹងសាទុក្ខកែតម្រូវ ត្រូវបានដាក់ជូននេះ គឺបន្សល់ទុកឲ្យអង្គជំនុំជម្រះ និងភាគីនានា មិនមានលទ្ធភាពអាចបង្ហាញការជាប់ទាក់ទងគ្នារវាង *ខ្លឹមសារ* របស់វា ទៅនឹងទឡ្ហីករណ៍នានានៃបណ្តឹងសាទុក្ខតាមលេខរៀង ក្នុងការជូនដំណឹងបណ្តឹងសាទុក្ខ[11]។

7. ថ្វីបើមានសំណើសុំឲ្យមានការបញ្ជាក់ក៏ដោយ ក៏នៅក្នុងចម្លើយតបរបស់ខ្លួន មេធាវីការពារក្តីបានបន្តបន្ថែមទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខតាមរបៀបជា អត្ថបទទូទៅទាំងស្រុង - ដែលគេហៅថា

---

[10] សំណើ, កំណត់សម្គាល់*ខាងលើ* លេខ៣ ត្រង់កថាខណ្ឌទី៣។

[11] *ដដែលដូចមុន*, ត្រង់កថាខណ្ឌទី៥ [សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*]។

"ប្រភេទ" នៃវិការៈដែលបានចោទប្រកាន់[12]។ បញ្ហានេះគឺត្រូវបានធ្វើឲ្យធ្ងន់ធ្ងរឡើង ដោយកង្វះសេចក្តីយោងទៅដល់ទឡ្ហីករណ៍បណ្តឹងសាទុក្ខដែលវាយលេខ ឬដែលបានដាក់ឈ្មោះ នៅក្នុងបណ្តឹងសាទុក្ខកែតម្រូវនោះ។ ទន្ទឹមនេះ មិនច្បាស់ថាតើមានទឡ្ហីករណ៍និមួយៗទាំងប៉ុន្មាននៃបណ្តឹងសាទុក្ខនេះកំពុងលើកឡើងដោយមេធាវីការពារក្តី ហើយការបញ្ជាក់រវាងទឡ្ហីករណ៍ទាំងនោះ អាចកុហក។ លើសពីនេះទៀត បណ្តឹងសាទុក្ខកែតម្រូវ ខកខានមិនបានកំណត់ពីប្រភេទនៃកំហុសនិមួយៗដូចបានចោទប្រកាន់ឡើយ (ដូចជា ថាតើជាកំហុសអង្គច្បាប់ កំហុសអង្គហេតុ ឬជាកំហុសដែលគេអាចយល់បាននៅក្នុងការប្រើឆន្ទានុសិទ្ធិ ឬជាកំហុសរួម) ហើយដែលបទដ្ឋានត្រឹមត្រូវសម្រាប់ការពិនិត្យឡើងវិញដែលត្រូវអនុវត្តនោះ មិនច្បាស់លាស់។

8. ជាឧទាហរណ៍ មេធាវីការពារក្តីចោទប្រកាន់អំពីកំហុសអង្គច្បាប់ទាក់ទិននឹងនិយមន័យនៃធាតុផ្សំសហឧក្រិដ្ឋកម្មរួម (JCE) ទាំងអស់ ដែលស្ថិតនៅក្រោមចំណងជើងទូទៅនៃ "JCE"[13] ប៉ុន្តែមិនបានកំណត់អំពីទឡ្ហីករណ៍ជាក់លាក់ណាមួយនៃបណ្តឹងសាទុក្ខ នៅក្រោមជំពូកនេះទេ។ ការពិនិត្យឡើងវិញមួយចំពោះវាក្យខណ្ឌនេះ ការបកស្រាយមួយអាចបង្ហាញថា យ៉ាងហោចណាស់មានអំណះអំណាងខុសគ្នាចំនួនប្រាំ៖ គឺថា គ្មានផែនការរួម, ផែនការដែល ខៀវ សំផន បានចូលរួម មិនមែនជាឧក្រិដ្ឋកម្ម, ថាអង្គជំនុំជម្រះបានកំណត់មិនត្រឹមត្រូវចំពោះលក្ខខណ្ឌតម្រូវផ្នែកច្បាប់លក្ខណៈអត្តនោម័ត នៃ JCE III ទៅជា JCE I, នោះអង្គជំនុំជម្រះបំពានលើវិសាលភាពនៃយុត្តាធិការពេលវេលារបស់តុលាការ ហើយថាអង្គជំនុំជម្រះមានកំហុសនៅក្នុងការអនុវត្តបទដ្ឋាននៃការបង្ហាញភស្តុតាង[14]។ អំណះអំណាងណាមួយនៃអំណះអំណាងទាំងនេះ អាចគាំទ្រចំពោះទឡ្ហីករណ៍និមួយៗនៃបណ្តឹងសាទុក្ខបាន ចំពោះកំហុសអង្គច្បាប់ កំហុសអង្គហេតុ ឬជាកំហុសអង្គហេតុ និងអង្គហេតុរួម ដូចដែលបានចោទប្រកាន់នោះ។

9. ក្នុងករណីដែលមេធាវីការពារក្តីខកខានមិនបានផ្តល់ឈ្មោះ ចុះបញ្ជី និងចាត់ជំពូកនៃកំហុសទាំងឡាយដូចដែលបានចោទប្រកាន់ នៅក្នុងឧទាហរណ៍ដែលបានផ្តល់ការណ៍នេះនឹងត្រូវធ្លាក់មកលើសហព្រះរាជអាជ្ញាដែលត្រូវធ្វើការងារនេះ នៅក្នុងចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ខ្លួន។

---

[12] *ដដែលដូចមុន*, ត្រង់កថាខណ្ឌទី៩ ["En effet, les paragraphes d'une déclaration d'appel concernent une ou plusiers erreurs alléguées tandis que des moyens d'appel sont des **categories** d'erreurs alléguées." ]។[សង្កត់ន័យបន្ថែមដោយ**អក្សរដិតក្រាស់**]។

[13] សេចក្តីជូនដំណឹង, កំណត់សំគាល់*ខាងដើម* លេខ១ ត្រង់កថាខណ្ឌ៤៥។ បណ្តឹងសាទុក្ខត្រឹមត្រូវ, ត្រង់កថាខណ្ឌ៦៨-៧៣។

[14] បណ្តឹងសាទុក្ខត្រឹមត្រូវ, កំណត់សំគាល់*ខាងដើម* លេខ២ ត្រង់កថាខណ្ឌ៦៨-៧៣។

ការណ៍នេះមានការយល់ច្រឡំ និងគ្មានសមត្ថភាព ដោយសារ សហព្រះរាជអាជ្ញាអាចធ្វើការវិភាគ និងចាត់ជំពូកទឡ្ហីករណ៍ខុសពីចេតនារបស់មេធាវីការពារក្តីដែលចង់បាន។ ជាបន្តទៀត នឹងធ្លាក់ទៅលើអង្គជំនុំជម្រះដែលត្រូវធ្វើការវាយតម្លៃ និងចាត់ជំពូកឡើងវិញ ចំពោះទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងនោះ ហើយកំណត់ពីបទដ្ឋានត្រឹមត្រូវសម្រាប់ការពិនិត្យឡើងវិញ ដែលត្រូវអនុវត្តក្នុងកាលៈទេសៈទាំងនោះ។ ប្រសិនបើ ការវាយតម្លៃនេះខុសពីការយល់ដឹងរបស់សហព្រះរាជអាជ្ញា នោះអង្គជំនុំជម្រះមិនអាចមានចម្លើយតបចំចំណុចបានឡើយ។

10. បន្ថែមទៀត មានអំណះអំណាងមួយចំនួនដែលបានលើកឡើងដោយមេធាវីការពារក្តី នៅត្រង់ចំណុចខុសៗគ្នានៅក្នុងបណ្តឹងសាទុក្ខកែតម្រូវនោះ ដែលហាក់ដូចជាមានការពាក់ព័ន្ធនឹងទឡ្ហីករណ៍ដូចគ្នានៃបណ្តឹងសាទុក្ខ ឬដែលម្យ៉ាងទៀតអាចគាំទ្រទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខដែលពាក់ព័ន្ធបានច្រើន។ ទាក់ទិនចំណុចនេះ បណ្តឹងសាទុក្ខកែតម្រូវធ្វើឱ្យសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី មិនច្បាស់លាស់ និងគ្មានការកំណត់ន័យប្រាកដប្រជា។ ជាឧទាហរណ៍ បញ្ហាអំពីការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវបានដោះស្រាយយ៉ាងហោចណាស់ដប់បួនដង នៅក្នុងបណ្តឹងសាទុក្ខកែតម្រូវ[15] ដោយគ្មានការបញ្ជាក់អំពីរបៀបដែលមេធាវីការពារក្តីចង់ឱ្យអង្គជំនុំជម្រះពិនិត្យឡើងវិញ ទៅលើអំណះអំណាងនិមួយៗឡើយ។

11. គេនៅតែមិនច្បាស់ សូម្បីតែមានសេចក្តីយោងទៅនឹងតារាងដែលបានផ្តល់ឱ្យដោយមេធាវីការពារក្តី នៅក្នុងឧបសម្ព័ន្ធនៃចម្លើយតបនោះក្តី ថាតើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខណាមួយដែលអាចថាបានបោះបង់ចោល និងធានាមិនឱ្យមានការវាយតម្លៃបន្ថែមពីអង្គជំនុំជម្រះ។ ត្រង់នេះអាស្រ័យដោយសារការពិតដែលថា ខណៈដែល*រចនាសម្ព័ន្ធ* នៃសេចក្តីជូនដំណឹង និងបណ្តឹងសាទុក្ខកែតម្រូវមិនខុសគ្នាច្រើនក្តី ក៏នៅក្នុងតួយ៉ាងដូចជា *ខ្លឹមសារ* នៃបណ្តឹងសាទុក្ខកែតម្រូវ មិនពាក់ព័ន្ធគ្នាដោយស្រួលៗនោះទេជាមួយទឡ្ហីករណ៍បណ្តឹងសាទុក្ខ ដូចបានរៀបរាប់នៅក្នុងសេចក្តីជូនដំណឹង[16]។ ជាផលប្រយោជន៍សម្រាប់ភាគីទាំងអស់ដែលត្រូវយល់ឱ្យបានច្បាស់ ថាតើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ

[15] **F17/Corr. 1** Mémoire d'appel de la Défense de M.KHIEU Samphân contre le jugement rendu dans le procès 002/01, ៣១ ធ្នូ ២០១៤ ត្រង់ ERN ជាភាសាបារាំង 01052205 និងបណ្តឹងសាទុក្ខត្រឹមត្រូវ, *ដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ 11-12, 14, 47, 192, 288, 330, 339, 340, 426, 427, 484, 490, 496, 644 និង 645។

[16] ជាងនេះទៀត ឧបសម្ព័ន្ធឃើញថាមានវិការៈជាច្រើនផ្អែកតាមសិទ្ធិរបស់គេ។ ឧទាហរណ៍ យោងទៅតាមតារាងដែលបានផ្តល់ជូន ភាគីអាចសន្និដ្ឋានថា ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខទាំងអស់ដែលបានកំណត់ក្នុងកថាខណ្ឌទី៦ ដល់១១៩ នៃការជូនដំណឹងបណ្តឹងសាទុក្ខ បានបញ្ចូលទៅក្នុងកថាខណ្ឌទី១១ នៃបណ្តឹងសាទុក្ខកែតម្រូវ។ ទោះបីជាយ៉ាងណាក៏ដោយ តារាងក៏បានបង្ហាញផងដែរថា កថាខណ្ឌ៦២ ដល់១១៩ ផ្ទុយទៅវិញ បានផ្លាស់ប្តូរកន្លែង ឬបញ្ចូលជាមួយកថាខណ្ឌផ្សេងៗទៀតជាច្រើនក្នុងបណ្តឹងសាទុក្ខកែតម្រូវ។

ដែលមេធាវីការពារក្ដីមានបំណងយកមក និងទឡ្ហីករណ៍ណាដែលមេធាវីការពារក្ដីអាចជ្រើសរើសបោះបង់ចោល។

## IV. សេចក្ដីសន្និដ្ឋាន

ដូចមូលហេតុជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ចម្លើយតបដែលបានផ្ដល់ដោយមេធាវីការពារក្ដី មិនបានលុបលាងគ្រប់គ្រាន់ចំពោះវិការៈទាំងឡាយ ដូចបានកំណត់ក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួនឡើយ។ ទន្ទឹមនេះ សហព្រះរាជអាជ្ញានៅតែប្រកាន់ជំហរចំពោះសំណើរបស់ខ្លួនសុំឲ្យអង្គជំនុំជម្រះ បង្គាប់ទៅមេធាវីការពារក្ដីឲ្យដាក់ឯកសារបន្ថែម ទៅនឹងបណ្ដឹងសាទុក្ខកែតម្រូវរបស់ខ្លួន ដោយបញ្ជាក់អំពីទឡ្ហីករណ៍ណាមួយនៃបណ្ដឹងសាទុក្ខ បានដោះស្រាយនៅក្នុងបណ្ដឹងសាទុក្ខកែតម្រូវ ហើយទឡ្ហីករណ៍នីមួយៗគាំទ្រមូលហេតុនៃបណ្ដឹងសាទុក្ខត្រង់ណា។

12. សហព្រះរាជអាជ្ញាមិនស្នើឲ្យចេញការបង្គាប់ទៅមេធាវីការពារក្ដី ឲ្យធ្វើពង្រាងបណ្ដឹងសាទុក្ខកែតម្រូវរបស់ខ្លួនឡើងវិញទេ។ ផ្ទុយទៅវិញ ស្នើឲ្យចេញការបង្គាប់ឲ្យមេធាវីការពារក្ដី ផ្ដល់លិខិតក្រមបន្ថែមចំពោះបណ្ដឹងសាទុក្ខកែតម្រូវ ៖ (i) រាយឈ្មោះទឡ្ហីករណ៍និមួយៗនៃបណ្ដឹងសាទុក្ខ ដែលចោទប្រកាន់ ដោយយោងត្រូវទៅនឹងកថាខណ្ឌក្នុងការជូនដំណឹងបណ្ដឹងសាទុក្ខ, (ii) រៀបរាប់ ឬប្រាប់ឈ្មោះទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខ និង (iii) ដាក់ប្រភេទទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខដែលមានកំហុសអង្គហេតុ អង្គច្បាប់ ឆន្ទានុសិទ្ធិ ឬកំហុសរួម។ លិខិតក្រមស្រដៀងគ្នានេះ ត្រូវបានផ្ដល់ដោយមេធាវីការពារក្ដី នួន ជា នៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន ដែលសេចក្ដីដកស្រង់មួយនៃលិខិតក្រមត្រូវបានដាក់ជូនជា **ឧបសម្ព័ន្ធ ១** ទៅនឹងចម្លើយតបនេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | |